**សកម្មភាព** ៖ ល្បែងក្រុមពណ៌

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។

បំណិនចលកធំ (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំតូច និងសាច់ដុំធំ)។

**បុរេគណិត**

ទំហំ និងពណ៌ (ចំណាត់ក្រុម និងលំដាប់លំដោយ)។

**គោលបំណង** ៖

**(ចិត្តចលភាព)** ប្រាប់ពីរបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬលេងល្បែង។

បង្ហាញពីរបៀបធ្វើសកម្មភាពទៅតាមទម្រង់ផ្សេងៗនៃសកម្មភាពរួមមួយ។

**(បុរេគណិត)** ប្រាប់បានពីរបៀបរៀបវត្ថុតាមលំដាប់ក្រុម ប្រភេទ ទំហំ និងពណ៌។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង "តើនរណាជាអ្នកលាបពណ៌មេឃ?"

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ក្រដាសពណ៌ ៧ពណ៌មានពណ៌ក្រហម ខៀវ លឿង បៃតង ទឹកក្រូច ស្វាយនិងពណ៌ខៀវស្វាយកាត់វាជារាងការ៉េ បន្ទាប់មកអ៊ុតវាឱ្យមានភាពរឹងមាំ មួយដុំមាន៧ពណ៌ ។

**ការរៀបចំ** ៖ ចែកកាតទៅឱ្យក្មេងៗតាមក្រុមម្នាក់ ១សន្លឹកតាមពណ៌នីមួយៗ។

កាតក្រហមអាចមាន ៣ទៅ ៥កាតអាស្រ័យចំនួនក្មេង។

ពេលខ្លះកាតមួយដុំមាន ៣ ទៅ៥ ពណ៌ក៏បានដែរ។

**សេចក្តីណែនាំ៖**

1. រៀបចំតុ ឬកៅអីដាក់នៅចំកណ្តាលឱ្យក្មេងៗទាំងអស់គ្នាឈរជារង្វង់ជុំវិញកៅអី ឬ តុនោះ។
2. អ្នកគ្រូបង្ហាញក្មេងៗពីកាតពណ៌ទាំង៧ ពណ៌មានពណ៌ក្រហម ខៀវ លឿង បៃតង ទឹកក្រូច ស្វាយ និងពណ៌ខៀវស្វាយ និងឱ្យក្មេងៗថាតាម។
3. ចែកកាតទាំងប្រាំពីរនោះទៅក្មេងៗម្នាក់ ១សន្លឹកតាមពណ៌នីមួយៗ ។
4. ឱ្យក្មេងៗដើរជុំវិញកៅអីដោយមិនឱ្យបង្ហាញកាតដែលខ្លួនឯងកំពុងកាន់ឱ្យអ្នកផ្សេងៗឃើញឡើយ។

5. បន្ទាប់ពីដើរមួយសន្ទុះសូមប្រាប់ឱ្យក្មេងៗឈប់ ហើយឱ្យពួកគេស្វែងរកកាតដែលមានពណ៌ដូចគ្នា ប្រសិនបើរកឃើញហើយ ត្រូវកាន់ដៃ ឬ ឈរជាក្រុមតាមពណ៌នីមួយៗ។
   ឧទាហរណ៍៖ ក្មេងមានកាតក្រហម ស្វែងរកក្មេងមានកាតក្រហមម្នាក់ទៀត។
   អាចមួយពណ៌មាន ៣ ទៅ ៥កាតអាស្រ័យចំនួនក្មេង។
6. ក្រោយពេលរកឃើញតាមក្រុមមានកាតដូចៗគ្នាតាមពណ៌នីមួយៗហើយ ត្រូវលើកកាតហើយនិយាយ
7. អ្នកអាចចាក់បទភ្លេងនៅពេលពួកគេកំពុងដើរ ហើយឱ្យក្មេងៗឈប់ដើរនៅពេលតន្ត្រីឈប់ក៏បាន។





**ការប្រែប្រួល៖**

អ្នកអាចលេងហ្គេមនេះជាមួយនឹងប្រធានបទផ្សេងៗទៀតបាន។ ធ្វើជាកាតដែលនិយាយពីប្រធានបទផ្សេងៗ ដូចជា៖ បន្លែ ផ្លែឈើ សត្វ... ល។